# សង្ខេប ចក្ខុវិស័យប្រទេសកម្ពុជា

## សន្និសីទចក្ខុវិស័យលើកទី ១៤

## ការស្តារកម្ពុជាឡើងវិញពីវិបត្តិនៃជំងឺកូវីដ-១៩៖ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព បន្ទាប់ពីជំងឺកូវីដ-១៩

ឧបត្ថម្ភដោយ

"រាជរដ្ឋាភិបាលបាន និងកំពុងព្យាយាមប្រែក្លាយវិបត្តិកូវីដ-១៩ ឱ្យទៅជាកាលានុវត្តភាព តាមរយៈការពន្លឿនការកែទម្រង់ស៊ីជម្រៅ ដើម្បីលើកកម្ពស់បរិយាកាសធុរកិច្ច និងពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា។"

*សុន្ទរកថាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*
*ថ្លែងក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី ១៤*

## ការអភិវឌ្ឍរបស់កម្ពុជា កំពុងស្ថិតនៅចំណុចបត់ដ៏សំខាន់

សន្និសីទចក្ខុវិស័យលើកទី ១៤ ដែលប្រារព្ធនៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២ បានប្រមូលផ្តុំនូវថ្នាក់ដឹកនាំ មកពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៃរាជរដ្ឋាភិបាលកម្ពុជា ស្ថានទូតបរទេស តំណាងបេសកកម្មការទូតបរទេសនានា ប្រចាំព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារអង្គការសហប្រជាជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ ស្ថាប័នអប់រំ វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងអង្គការមិនមែនរដ្ឋាភិបាល ជាតិ-អន្តរជាតិនៅប្រទេសកម្ពុជា ដើម្បីពិភាក្សាអំពីបញ្ហាសំខាន់ៗនានា។ សន្និសីទនេះ បានផ្តោតយ៉ាងសំខាន់ទៅលើការរិះរកគោលនយោបាយ ឆ្ពោះទៅមុខសម្រាប់ឱ្យកម្ពុជាសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាពនិងសម្រាប់គ្រប់គ្នានៅក្នុងបរិបទស្តារឡើងវិញក្រោយជំងឺកូវីដ-១៩និងដើម្បីធ្វើឱ្យកម្ពុជាទទួលបានឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ សង្ខេបគោលនយោបាយនេះ នឹងបង្ហាញពីការពិចារណាលើគោលនយោបាយដែលប្រមូលចេញពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២២ ដោយផ្តើមដំបូងលើការពិភាក្សាពីបញ្ហាប្រឈម និងឱកាស ដែលកម្ពុជានឹងប្រឈមមុខការផ្លាស់ប្តូរដែលគួរធ្វើសម្រាប់យុទ្ធសាស្ត្រសេដ្ឋកិច្ចមុនកូវីដរបស់កម្ពុជា និងសកម្មភាពបន្ទាន់ដែលដៃគូឯកជន-សាធារណៈ ត្រូវអនុវត្តដើម្បីអភិវឌ្ឍសេដ្ឋកិច្ច។

មុនការរាតត្បាតនៃជំងឺកូវីដ-១៩ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានលក្ខណៈល្អគួរឱ្យកត់សម្គាល់។ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៩ សេដ្ឋកិច្ចកម្ពុជាមានកំណើនប្រចាំឆ្នាំ ៧% ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសមានកំណើនសេដ្ឋកិច្ចលឿនបំផុតក្នុងពិភពលោក និងអាចឱ្យប្រទេសនេះសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥។ ទោះយ៉ាងណា នៅឆ្នាំ២០២០ ប្រទេសកម្ពុជាបានជួបប្រទះនូវវិបត្តិសេដ្ឋកិច្ចជាលើកដំបូងក្នុងរយៈពេល ៣០ឆ្នាំ ដោយបានបង្កើនបន្ទុកទៅលើប្រជាជនកម្ពុជាដែលងាយរងគ្រោះបំផុត។

ជំងឺកូវីដ-១៩ និងសម្ពាធពិភពលោកផ្សេងទៀត ក៏ដូចជាការរេចរឹលបរិស្ថាន អស្ថិរភាពភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចជាតិនិយម នៅតែបន្តជះឥទ្ធិពលដល់ការអភិវឌ្ឍរបស់ប្រទេស។ ដូចនេះហើយ កម្ពុជាត្រូវការទិសដៅថ្មីដែលអាចជួយឱ្យកម្ពុជាយកឈ្នះលើបញ្ហាប្រឈមមុខថ្មីនៅក្នុងបរិបទពិភពលោកដែលផ្លាស់ប្តូរជាបន្តបន្ទាប់។

បើផ្អែកលើផ្នែកសេដ្ឋកិច្ច យើងឃើញថាគំរូកំណើនរបស់កម្ពុជា ត្រូវការធ្វើពិពិធកម្ម និងការធ្វើឱ្យប្រសើរឡើងទៅលើវិស័យឧស្សាហកម្មឱ្យកាន់តែច្រើន ជាពិសេសត្រូវផ្តោតទៅលើឱកាសបច្ចេកវិទ្យាឌីជីថល។ កំណើនផលិតផលក្នុងស្រុកសរុប របស់កម្ពុជាក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ មានទំហំតូចជាង បើធៀបនឹងប្រទេសផ្សេងទៀតនៅក្នុងតំបន់ដែលមានមូលដ្ឋាននាំចេញចម្រុះច្រើនជាងប្រទេសកម្ពុជា។ ប្រទេសកម្ពុជាក៏អាចប្រឈមមុខនឹងហានិភ័យខាងភូមិសាស្ត្រនយោបាយ ដែលកើតចេញពីសង្គ្រាមនៅប្រទេសអ៊ុយក្រែន ដែលតម្រូវឱ្យកម្ពុជារក្សាជំហរប្រកបដោយតុល្យភាពនៅក្នុងពិភពលោកថ្មីនេះ។

ចំពោះផ្នែកបរិស្ថាននៅប្រទេសកម្ពុជា ការប្រែប្រួលអាកាសធាតុ ការកាប់បំផ្លាញព្រៃឈើ និងអភិបាលកិច្ចធនធានទឹកកសិកម្មនៅទន្លេមេគង្គ បានគំរាមកំហែងដល់ប្រជាជននៅជនបទដែលពឹងផ្អែកលើវិស័យកសិកម្ម។ បម្រែបម្រួលបរិស្ថាន ដែលកើតឡើងដោយការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចធនធានទឹក គឺជាបញ្ហាសំខាន់ដោយយោងលើសារៈសំខាន់នៃវិស័យនេះសម្រាប់ភាពធន់នឹងការចិញ្ចឹមជីវិតរបស់ប្រជាជនរស់នៅតាមតំបន់ជនបទនៅកម្ពុជា។

ជាចុងក្រោយ យុទ្ធសាស្ត្រអភិវឌ្ឍន៍នាពេលអនាគត ត្រូវពង្រីកវិសាលភាពពីភាពក្រីក្រពហុវិមាត្រ និងសូចនាករសង្គម។ ជីវភាពរស់នៅមិនត្រូវបានកំណត់ត្រឹមតែប្រាក់ចំណូលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវកំណត់លើសន្តិសុខស្បៀង លទ្ធភាពទទួលបានហេដ្ឋារចនាសម្ពន្ធ័មូលដ្ឋាន ឱកាសទទួលបានការអប់រំ និងការយល់ដឹងអំពីការផ្តល់សិទ្ធិអំណាច។

# ឥទ្ធិពលនៃនិន្នាការធំៗជាសាកលមកលើកម្ពុជា

សន្និសីទបានកំណត់និន្នាការធំៗចំនួនបួន ដែលកម្ពុជាត្រូវពិចារណាក្នុងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន។ និន្នាការធំៗទាំងនេះ រួមបញ្ចូលទាំងភាពតានតឹងខាងភូមិសាស្ត្រនយោបាយ បម្រែបម្រួលអាកាសធាតុ បដិវត្តន៍ឧស្សាហកម្ម ៤.០ និងឌីជីថលនីយកម្ម និងការបង្កើនការគាំពារនិយមក្នុងតំបន់ រួមជាមួយនឹងការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក។

## ភាពតានតឹងខាងភូមិសាស្ត្រនយោបាយ

ការកើនឡើងនូវភាពតានតឹងរវាង សហរដ្ឋអាមេរិក និង សាធារណរដ្ឋប្រជាមានិតចិន និងសង្គ្រាមរវាងអ៊ុយក្រែននិងរុស្ស៊ី បង្កើតបានជាទិដ្ឋភាពភូមិសាស្ត្រនយោបាយបច្ចុប្បន្ន ហើយវាបង្កជាហានិភ័យដល់សន្តិសុខស្ថិរភាព និងកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដែលជាក់ស្តែង ប្រទេសតូចៗជារឿយៗ ទទួលរងនូវផលប៉ះពាល់ខ្លាំង។ បញ្ហាទាំងនេះ បានបង្កើនសម្ពាធដល់អាយុជីវិត និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ជាពិសេសអ្នកក្រីក្រ និងអ្នកងាយរងគ្រោះបំផុត ដោយសារតម្លៃទំនិញកើនឡើង។ ដូចនេះហើយវាចាំបាច់ណាស់សម្រាប់ប្រទេសកម្ពុជា ក្នុងការស្វែងរកមធ្យោបាយជួយរក្សាសន្តិភាពពិភពលោក ដោយរក្សាស្វ័យភាពរបស់ខ្លួនក្នុងពេលជាមួយគ្នា។ ពហុភាគីនិយម និងកិច្ចសហប្រតិបត្តិការជាមួយ ដៃគូអន្តរជាតិ ក៏ជាគន្លឹះក្នុងការដោះស្រាយ បញ្ហាប្រឈមប្រកបដោយសន្តិវិធី និងទទួលបានអត្ថប្រយោជន៍ពីវេទិកាសាកល និងតំបន់។

## បម្រែបម្រួលអាកាសធាតុ

បម្រែបម្រួលអាកាសធាតុ បានជះឥទ្ធិពលកាន់តែខ្លាំងទៅលើសុខភាព និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងសេដ្ឋកិច្ចកម្ពុជាជាទូទៅ។ ការគ្រប់គ្រងមិនល្អទៅលើធនធានធម្មជាតិរបស់កម្ពុជា នឹងធ្វើឱ្យមានផលវិបាកយ៉ាងធ្ងន់ធ្ងរ ដល់ការអភិវឌ្ឍប្រទេសនាពេលអនាគត។ ការសម្រេចបាននូវគោលដៅសេដ្ឋកិច្ចរបស់កម្ពុជាប្រកបដោយប្រសិទ្ធភាព ត្រូវតែពាក់ព័ន្ធនឹងការលើកកម្ពស់សេដ្ឋកិច្ចបៃតង និងយុទ្ធសាស្ត្រភាពធន់នឹងអាកាសធាតុ។ ក្នុងការរៀបចំគម្រោងអភិវឌ្ឍន៍បៃតងនាពេលអនាគត កម្ពុជាមានឱកាសក្នុងគម្រោងមូលនិធិថាមពលកកើតឡើងវិញ និង គម្រោងកាត់បន្ថយអាកាសធាតុ និងការបន្សាំ។ ការផ្តល់មូលនិធិដល់គម្រោងបែបនេះ នឹងបង្កើតបរិយាកាសភាពធន់ដែលគាំទ្រដល់ វិស័យសេដ្ឋកិច្ចមានស្រាប់ និងផ្តល់ផលចំណេញខ្ពស់ដល់សេដ្ឋកិច្ចកម្ពុជា។ ក្រៅពីការបង្កើតការវិនិយោគទូលំទូលាយ លើអាកាសធាតុ កម្ពុជាក៏គួរស្វែងរកមូលនិធិពី ប្រភពឯកជននានា និងជំនួយអភិវឌ្ឍន៍ផ្លូវការ។

## បដិវត្តន៍ឧស្សាហកម្ម ៤.០ និងឌីជីថលនីយកម្ម

បដិវត្តន៍ឧស្សាហកម្ម ៤.០ បានផ្តោតយ៉ាងខ្លាំងទៅលើឌីជីថលនីយកម្ម ដែលនឹងតម្រូវឱ្យប្រទេសកម្ពុជាស្វែងរកដំណោះស្រាយប្រកបដោយនវានុវត្តន៍ ចំពោះបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងអនាគត ដើម្បីជំរុញកំណើនសេដ្ឋកិច្ចរបស់ខ្លួន។ ការបន្តវិនិយោគលើវិស័យឌីជីថលនីយកម្ម និងការកែលម្អធនធានមនុស្ស គឺជាវិធានការចាំបាច់ ដើម្បីជម្នះ និងសម្របខ្លួនទៅនឹងបញ្ហាប្រឈមដែលកំពុងកើតមាន។ អាទិភាពសំខាន់ៗឆ្ពោះទៅមុខ គួរតែជាការកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រកបដោយនិរន្តរភាព ដើម្បីបង្កើនឱកាសឌីជីថលនៅតាមតំបន់ជនបទ អាចផ្លាស់ប្តូរនគរូបនីយកម្ម ធ្វើឱ្យមានសេដ្ឋកិច្ចបៃតង និងលើកកម្ពស់ភាពធន់នឹងសេដ្ឋកិច្ចបានយ៉ាងឆាប់រហ័ស។ វិធានការបែបនេះ នឹងពង្រឹងសហគមន៍ និងគាំទ្រដល់ការធ្វើកសិកម្មខ្នាតតូច ដោយធ្វើសមាហរណកម្មសេដ្ឋកិច្ចជនបទ ទៅក្នុងខ្សែសង្វាក់តម្លៃជាតិ និងអន្តរជាតិ។

## ការគាំពារតំបន់និយម និងការធ្លាក់ចុះសេដ្ឋកិច្ចសាកល

ការរាតត្បាតនៃជំងឺកូវីដ-១៩ និងព្រឹត្តិការណ៍សាកលដែលកំពុងរីករាលដាល បានបង្កឱ្យមានផលប៉ះពាល់ដល់សុខភាព និងសង្គមក្នុងទំហំដែលមិនធ្លាប់មានពីមុនមក។ វិបត្តិសេដ្ឋកិច្ចពិភពលោក និងនិន្នាការថ្មីៗឆ្ពោះទៅរកជាតិនិយម និងគាំពារនិយមក្នុងតំបន់ បាននាំឱ្យមានការស្តារឡើងវិញនូវផលិតកម្មពីប្រទេសកំពុងអភិវឌ្ឍ ទៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់។

ប្រទេសកម្ពុជា អាចជំនះភាពចលាចលនៃសេដ្ឋកិច្ច និងយុទ្ធសាស្ត្រភូមិសាស្ត្រ ដែលប្រទេសនេះប្រឈម នាពេលបច្ចុប្បន្ន ប្រសិនបើយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច នាពេលអនាគតរបស់ខ្លួន គឺផ្អែកលើកំណើនយ៉ាងឆាប់រហ័ស ប្រើប្រាស់បានយូរសម្រាប់គ្រប់គ្នា និងមាននិរន្តរភាព។ កត្តាមួយដែលពាក់ព័ន្ធនឹងការសម្រេចបាននូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ដ៏ត្រឹមត្រូវ ហើយនៅតែត្រូវការដោះស្រាយនោះ គឺការវិវត្តនៃការកំណត់គោលនយោបាយរូបិយវត្ថុខុសពីធម្មតារបស់កម្ពុជា រួមនឹងកិច្ចខិតខំប្រឹងប្រែងកៀរគរធនធានឱ្យបានកាន់តែច្រើនខណៈប្រទេសបានវិវត្តពីប្រទេសដែលអភិវឌ្ឍន៍តិចតួច និងបានបំពេញបន្ថែមដោយ វិធានការបង្កើនភាពប្រកួតប្រជែងផ្នែកផ្គត់ផ្គង់ ដោយបញ្ឈប់របបលើកទឹកចិត្តពាណិជ្ជកម្ម 'ទូរ' និងកំណែទម្រង់ក្របខ័ណ្ឌលើកទឹកចិត្តសារពើពន្ធ។



រូបថត៖ https://www.google.com/search

## ការអភិវឌ្ឍមុនកូវីដ និងការប្ដូរយុទ្ធសាស្ត្ររបស់កម្ពុជា ដើម្បីទទួលបានការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់នាពេលអនាគត

ការអភិវឌ្ឍមុនពេលមានកូវីដរបស់កម្ពុជា ទទួលបានជោគជ័យយ៉ាងខ្លាំង ទោះយ៉ាងណា ភាពមិនប្រាកដប្រជា និងការរំខានទាំងក្នុងកម្រិតតំបន់ និងសាកលលោក បានប៉ះពាល់ទៅលើគំរូអភិវឌ្ឍនេះ។ ការពឹងផ្អែកលើវិស័យសេដ្ឋកិច្ចចំនួនបួន (ទេសចរណ៍ សំណង់និងអចលនទ្រព្យ កសិកម្ម និងផលិតកម្ម) មានអស្ថិរភាព នៅពេលវិស័យទាំងបួនត្រូវរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារកូវីដ-១៩ និងវិបត្តិសេដ្ឋកិច្ចសាកល។ ការដំឡើងប្រាក់ឈ្នួល គឺមិនស៊ីគ្នានឹងកំណើនផលិតភាព និងគុណភាពទំនិញ ដែលបានកាត់បន្ថយភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងទីផ្សារពិភពលោក។ ការកែសម្រួលទិសដៅគោលនយោបាយមុនពេលមានកូវីដ នឹងធានាដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចបានច្រើន និងសម្រេចបាននូវគោលដៅរបស់រដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន។

### កសាងភាពធន់ក្នុងមូលដ្ឋាន សម្រាប់ប្រកបចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព

ជំងឺរាតត្បាតកូវីដ-១៩ បានបញ្ជាក់ពីសារៈសំខាន់នៃការកសាងភាពធន់ខាងសន្តិសុខសុខភាព ដែលពាក់ព័ន្ធនឹងការពង្រឹងប្រព័ន្ធថែទាំសុខភាព និងការគាំពារសង្គម ដើម្បីកាត់បន្ថយផលប៉ះពាល់អាក្រក់លើសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន។ ការផ្ដល់មូលដ្ឋានគ្រឹះដ៏រឹងមាំដែលផ្អែកលើការអប់រំ និងការបណ្ដុះបណ្ដាលជំនាញ សម្រាប់កម្លាំងពលកម្មបច្ចុប្បន្ន និងអនាគត នឹងបង្កើតភាពធន់ចាំបាច់ជាច្រើនក្នុងការថែទាំសុខភាព។

កំណើនកម្រិតបំណុល ធនាគារ និងគ្រួសារ គឺជាលទ្ធផលនៃការប៉ះពាល់ដោយជំងឺរាតត្បាត ហើយការធ្លាក់ចុះសេដ្ឋកិច្ច បានបំផ្លាញភាពធន់ទៅលើផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើការជាប់បំណុលនេះ ត្រូវបានដោះស្រាយបន្តិចម្ដងៗ នោះវាអាចនឹងបញ្ចៀស ពីការដួលរលំហិរញ្ញវត្ថុដ៏គ្រោះថ្នាក់នេះបាន។ លើសពីនេះ ការបង្កើនបទប្បញ្ញត្តិ និងការត្រួតពិនិត្យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចសម្រេចបាននូវនិរន្តរភាពហិរញ្ញវត្ថុរយៈពេលវែង។

ប្រជាជនវ័យក្មេងជាច្រើនរបស់ប្រទេសកម្ពុជា និងការទទួលយកបច្ចេកវិទ្យាឌីជីថល ផ្តល់ឱកាសគាំទ្រដល់ប្រភពការងារ និងឧស្សាហកម្មថ្មីៗ សម្រាប់ពិពិធកម្មសេដ្ឋកិច្ចឆ្ពោះទៅមុខ។ តាមរយៈការបង្កើនការវិនិយោគរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងតុល្យភាពវិសមភាពដែលកំពុងកើតមានរវាងប្រជាជនជនបទ ជនជាតិភាគតិច និងប្រជាជននៅទីក្រុង កម្ពុជាអាចបង្កើតវិធីសាស្ត្រថ្មីឆ្ពោះទៅរកការស្តារឡើងវិញក្រោយវិបត្តិកូវីដ។

## ពង្រឹងគណនេយ្យភាពស្ថាប័ន និងតម្លាភាពវិស័យហិរញ្ញវត្ថុ និងសេវាសាធារណៈ

សេវាសាធារណៈរបស់កម្ពុជា នៅតែទាមទារឱ្យមានការកែលម្អ។ ការកែលម្អបែបនេះ គឺជាគន្លឹះក្នុងការរក្សាស្ថាប័នឯករាជ្យ អាចដំណើរការដោយគ្មានសម្ពាធនយោបាយ និងការជ្រៀតជ្រែក។ ចំណុចសំខាន់ត្រូវយកចិត្តទុកដាក់ គឺការជំរុញប្រព័ន្ធធនាគារដែលគ្រប់គ្រងបានល្អ ប្រព័ន្ធពន្ធដារ និងការប្រកួតប្រជែង ដើម្បីធានាបាននូវកម្រិតតួនាទីបានសមហេតុផល។ ចំណុចព្រួយបារម្ភសំខាន់មួយទៀត ជាពិសេសសម្រាប់កសិករ និងសហគមន៍ខ្នាតតូច គឺប្រព័ន្ធតុលាការ ដែលគ្របដណ្តប់លើវិវាទនានា ដែលទាក់ទងនឹងកម្មសិទ្ធិដីធ្លី។

ការបន្តអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានចាប់ផ្តើមមុនជំងឺរាតត្បាត គឺជាកត្តាសំខាន់ក្នុងការបង្កើតបរិយាកាសធុរកិច្ចល្អ នឹងជួយជំរុញដល់កំណើនសេដ្ឋកិច្ច។ លើសពីនេះ អភិបាលកិច្ចល្អ គឺជាមូលដ្ឋានយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី៤។

មូលដ្ឋានគ្រឹះនៃបរិយាកាសធុរកិច្ចដែលល្អ ស្ថិតនៅលើ៖ អភិបាលកិច្ចដែលឆ្លើយតបនឹង តម្រូវការគ្រប់ស្រទាប់សង្គម បរិយាកាសពាណិជ្ជកម្ម ដែលការប្រកួតប្រជែងមានឥទ្ធិពលលើអាជីវកម្មជោគជ័យ និងអភិវឌ្ឍន៍ការត្រួតពិនិត្យ និងតុល្យភាពប្រកបដោយតម្លាភាព លើការប្រព្រឹត្តខុសក្នុងវិស័យសាធារណៈ។ កម្ពុជាអាចរៀនពីប្រទេសជិតខាងរបស់ខ្លួននៅអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ ដែលបានបង្កើតគំរូគណនេយ្យភាពនយោបាយផ្ទាល់មានកម្រិត អាចស្របគ្នានឹងអភិបាលកិច្ចដែលតំណាង និងឆ្លើយតបបាន។

## ពង្រីកឧស្សាហកម្មថ្មី សម្រាប់ប្រភពកំណើនទូលំទូលាយ និងចម្រុះ

ដោយសារមានការរីកចម្រើនខ្លាំងផ្នែកសំណង់ និងអចលនវត្ថុ កំណើននាពេលអនាគត ត្រូវតែមកពីការធ្វើពិពិធកម្មទៅលើវិស័យកសិកម្ម និងផលិតកម្ម ជាពិសេសតាមរយៈការឆ្ពោះទៅរក សកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់។ ការធ្វើឱ្យប្រសើរឡើងនៃវិស័យទេសចរណ៍ ដែលសម្របនឹងភ្ញៀវទេសចរ ដែលមានការចំណាយខ្ពស់នឹងជំរុញវិស័យនេះឱ្យងើបឡើងវិញ។ វិស័យកសិកម្ម និងផលិតកម្ម អាចត្រូវបានពង្រឹងបន្ថែមទៀត ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា ទាញយកអត្ថប្រយោជន៍ពីឱកាសដែលមានបច្ចុប្បន្ន ដូចជា ការកែច្នៃទំនិញកសិកម្មនៅក្នុងប្រទេស ដើម្បីទទួលបានតម្លៃកាន់តែច្រើន ក៏ដូចជាការដាំដុះដំណាំដែលកំពុងស្វែងរកទីផ្សារនាំចេញ ដើម្បីបង្កើនឱកាស និងអត្ថប្រយោជន៍ដល់កសិករដោយផ្ទាល់។ ប្រសិនបើគុណភាពផលិតផលពីឧស្សាហកម្មជាប្រពៃណីត្រូវបានកែលម្អ នោះប្រទេសកម្ពុជាអាចត្រូវគេស្គាល់ថា ជាប្រទេសដែលនាំចេញផលិតផលមានគុណភាពខ្ពស់ នោះនឹងមានលទ្ធភាពទទួលបានទីផ្សារថ្មី។ ខណៈពេលដែលប្រទេសនេះ នឹងពង្រឹងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចរបស់ខ្លួន អាជីវកម្មក្នុងស្រុកអាចភ្ជាប់ជាមួយខ្សែសង្វាក់តម្លៃក្នុងតំបន់ និងពិភពលោក ដើម្បីពង្រឹងការអភិវឌ្ឍក្រោយកូវីដបាន។

## ជំរុញការអភិវឌ្ឍក្នុងតំបន់ និងមូលដ្ឋាន ដើម្បីដោះស្រាយវិសមភាព

វិសមភាពក្នុងតំបន់កំពុងរីកធំឡើង ជាពិសេសវិសមភាពរវាងសេដ្ឋកិច្ចនៅតាមជនបទ និងទីក្រុង។ ភាគច្រើននៃប្រជាជនកម្ពុជា រស់នៅតំបន់ជនបទ ហើយភាពក្រីក្រភាគច្រើន ក៏ប្រមូលផ្តុំនៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាលដែរ។ ទំនាក់ទំនងរវាងសេដ្ឋកិច្ចនៅជនបទ និងនៅទីក្រុង ជាពិសេសវិស័យកសិកម្មខ្នាតតូច វិស័យធុរកិច្ចក្រៅផ្លូវការ និងវិស័យផលិតកម្ម ឬសេវាកម្មក្នុងទីក្រុងផ្លូវការ ប្រហែលជាត្រូវរៀបចំឡើងវិញ ដើម្បីពង្រីកជម្រើសសម្រាប់គ្រួសាររាប់លាន ដែលរួមបញ្ចូលនូវយុទ្ធសាស្ត្រចិញ្ចឹមជីវិតក្នុងវិស័យទាំងបីនេះ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រោយកូវីដ ត្រូវទាញយកពី អត្ថប្រយោជន៍ក្នុងតំបន់ប្រៀបធៀបរបស់កម្ពុជាក្នុងវិស័យកសិកម្ម និង

ចំនួនប្រជាជនវ័យក្មេងដ៏ច្រើនរបស់ខ្លួន សម្រាប់ចក្ខុវិស័យរបស់កម្ពុជា ក្នុងការសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងលើកកម្ពស់គុណភាពឱ្យកាន់តែប្រសើរ រវាងវិស័យសំខាន់ៗចំនួនបី៖ សេដ្ឋកិច្ចផ្អែកលើជនបទ ការផលិតផ្តោតលើការនាំចេញ និងជំនាញទាប និងឧស្សាហកម្មមានជំនាញខ្ពស់ ដែលកំពុងលេចឡើង ជំរុញដោយបដិវត្តន៍ឧស្សាហកម្ម ៤.០។

## អាទិភាព និងសកម្មភាពបន្ទាន់ សម្រាប់ភាពជាដៃគូរវាងរដ្ឋាភិបាល និងធុរកិច្ច ដើម្បីជំរុញការអភិវឌ្ឍយូរអង្វែងប្រកបដោយបរិយាប័ន្ន

ភាពជាដៃគូនវានុវត្តន៍សាធារណៈ និងឯកជន អាចកំណត់ និងដាក់ជាអាទិភាពចំពោះបញ្ហាប្រឈមសេដ្ឋកិច្ចដែលកម្ពុជាប្រឈមមុខ ហើយនឹងត្រូវបំពេញបានយ៉ាងល្អក្នុងការកែលំអដំណោះស្រាយ ឆ្លើយតបនឹងបញ្ហាប្រឈមនានា។ ភាពជាដៃគូទាំងនេះ ពឹងផ្អែកលើការចូលរួមរបស់តួអង្គក្នុងស្រុក ហើយទាមទារនូវការកសាងសមត្ថភាព និងបង្កើតវប្បធម៌សហការដោយមានការជឿទុកចិត្ត។ ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ក៏អាចពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយមានស្រាប់ កំណែទម្រង់ប្រព័ន្ធពន្ធដារ ការគាំទ្រដល់សហគ្រិនស្ត្រី និងសហគ្រាសធុនតូចនិងមធ្យម និងបរិស្ថានសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍។

### វិស័យឯកជនគាំទ្រគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ឯកសារ "ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់ការស្តារសេដ្ឋកិច្ចក្នុងបរិបទរស់នៅជាមួយកូវីដ-១៩ ក្នុងការអភិវឌ្ឍតាមគន្លងប្រក្រតីភាពថ្មី ឆ្នាំ២០២១-២៣" ណែនាំសកម្មភាពយុទ្ធសាស្ត្ររយៈពេលវែងរបស់កម្ពុជារួមទាំង ការពង្រឹងសសរស្តម្ភសេដ្ឋកិច្ចមានស្រាប់ចំនួនបួន៖ ទេសចរណ៍ សំណង់និងអចលនទ្រព្យ កសិកម្ម និងផលិតកម្ម។ តាមរយៈកិច្ចសហការគ្នា និងការស្រាវជ្រាវ ក្រសួងពាក់ព័ន្ធ ស្ថាប័នសិក្សា និងក្រុមអ្នកផ្តល់គំនិត អាចកំណត់វិធីស្តារសសរស្តម្ភសេដ្ឋកិច្ចទាំងបួន។ ជាឧទាហរណ៍ ការស្រាវជ្រាវនានា អាចផ្តោតទៅលើកត្តាដែលរារាំងដល់ ការផលិតបន្លែក្នុងស្រុក និងពិពិធកម្មដំណាំ ដើម្បីបង្កើនផលិតភាពវិស័យកសិកម្មក្នុងប្រទេស។

នៅពេលកំណែទម្រង់ពន្ធ មានភាពប្រសើរឡើងខ្លាំង ការកែលម្អជាច្រើននៅតែត្រូវធ្វើបន្តទៀត។ ដោយសារការយកពន្ធ គឺជាប្រភពចំណូលដ៏សំខាន់របស់រដ្ឋាភិបាល ការមានប្រព័ន្ធពន្ធដារប្រកបដោយប្រសិទ្ធភាព សមធម៌ និងវិជ្ជាជីវៈ គឺជាគន្លឹះសម្រាប់ការអភិវឌ្ឍនាពេលអនាគត។ អគ្គនាយកដ្ឋានពន្ធដារ មានយុទ្ធសាស្ត្រ ផ្តោតលើការប្រមូលចំណូលដោយផ្អែកលើអភិបាលកិច្ចល្អ ជាពិសេសផ្តោតលើកំណែទម្រង់ធនធានមនុស្ស និងវិជ្ជាជីវៈ។ កំណែទម្រង់ទាំងនេះ បាននាំឱ្យមានភាពជោគជ័យ និងនិរន្តរភាពតម្លៃពន្ធ។ ទោះយ៉ាងណា កិច្ចសហប្រតិបត្តិការបន្ថែមទៀតពីវិស័យឯកជន និងសាធារណៈ គឺត្រូវការជាចាំបាច់ ដើម្បីពង្រឹងការអនុវត្តការងាររបស់មន្ត្រីពន្ធដារ និងពង្រឹងប្រព័ន្ធពន្ធដារផងដែរ។ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍បាន រដ្ឋាភិបាល វិស័យឯកជន និងអ្នកផលិត មិនត្រូវពឹងផ្អែកទាំងស្រុងលើ ការលើកទឹកចិត្តខាងពន្ធដារនោះទេ ប៉ុន្តែត្រូវរួមគ្នាដោះស្រាយបញ្ហាផ្សេងទៀត ដូចជា ការកែលម្អលទ្ធភាពទទួលបានទីផ្សារ និងការដឹកជញ្ជូនទំនិញទៅកាន់ទីផ្សារ។ ជាចុងក្រោយ កិច្ចសហប្រតិបត្តិការកាន់តែធំ រវាងក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាល នឹងអាចជួយដោះស្រាយបញ្ហានានា ដែលវិស័យឯកជនជួបប្រទះ និងភាគីពាក់ព័ន្ធផ្សេងទៀតកាន់តែលឿន និងមានប្រសិទ្ធភាព។

### ការពង្រឹងសហគ្រាសធុនតូច និងមធ្យម

រដ្ឋាភិបាលបានទទួលស្គាល់ការចូលរួមចំណែករបស់សហគ្រាសធុនតូច និងមធ្យម ដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ទោះយ៉ាងណា សហគ្រិនស្ត្រី និងសហគ្រាសធុនតូចនិងមធ្យម នៅតែប្រឈមមុខនឹងបញ្ហាជាច្រើនដែលរឹតតែធ្ងន់ធ្ងរឡើង ដោយសារកូវីដ-១៩ និងវិបត្តិសេដ្ឋកិច្ចសាកល។ ប្រសិនបើរដ្ឋាភិបាលធ្វើការរួមគ្នាជាមួយសហគ្រាសធុនតូច និងមធ្យម ដើម្បីកសាងសមត្ថភាពរបស់ពួកគេ ដោយផ្តល់ការគាំទ្រ ការបណ្តុះបណ្តាល និងលទ្ធភាពទទួលបានបច្ចេកវិទ្យា សហគ្រាសធុនតូច និងមធ្យម អាចបន្តរួមចំណែក

ដល់ការស្តារសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចនាពេលអនាគត។

## ការផ្សារភ្ជាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) និងឧស្សាហកម្ម

ការបង្កើនការគាំទ្រដល់ ការស្រាវជ្រាវនិងអភិវឌ្ឍន៍នឹងជួយដល់ កំណើនសេដ្ឋកិច្ច របស់ប្រទេសកម្ពុជាក្នុងរយៈពេលវែង។ ការផ្តល់មូលនិធិរបស់រដ្ឋាភិបាលនឹងមានសារៈសំខាន់ ក្នុងការលើកកម្ពស់ភាពជាដៃគូដោយផ្តោតលើ R&D រវាងសាកលវិទ្យាល័យ និងវិស័យឯកជន។ សាកលវិទ្យាល័យមានតួនាទីពិសេសក្នុងការជំរុញភាពជាដៃគូជាមួយវិស័យឯកជន។ ជាពិសេសសាកលវិទ្យាល័យ អាចបណ្តុះវប្បធម៌សហគ្រិន ដោយបង្កើតយន្តការ និងប្រព័ន្ធអេកូឡូស៊ី ដើម្បីលើកទឹកចិត្តដល់សាស្ត្រាចារ្យ និងនិស្សិត ឱ្យធ្វើកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន។

បច្ចេកវិទ្យាប្រព័ន្ធអេកូឡូស៊ី និងនវានុវត្តន៍ កំពុងកកើតឡើងជាលំដាប់នៅកម្ពុជា។ ច្បាប់ និងគោលនយោបាយដែលគាំទ្របច្ចេកវិទ្យា និងនវានុវត្តន៍ លើកកម្ពស់ភាពជាដៃគូរវាងសាកលវិទ្យាល័យ និងវិស័យឯកជន និងបង្កើតកិច្ចសន្ទនាដែលកំពុងបន្តរវាងរដ្ឋាភិបាល និងសាកលវិទ្យាល័យ នឹងជំរុញឱ្យប្រទេសកម្ពុជា ឆ្ពោះទៅរកគន្លងអភិវឌ្ឍន៍ដ៏រឹងមាំ សម្រាប់គ្រប់គ្នា និងប្រកបដោយចីរភាព។

## សង្ខេបគោលនយោបាយអាទិភាព ពីសន្និសីទចក្ខុវិស័យឆ្នាំ២០២២

គោលនយោបាយអាទិភាពខាងក្រោមត្រូវបានលើកឡើងនៅក្នុងសន្និសីទចក្ខុវិស័យ៖

១. ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានធម្មជាតិមិនបានល្អ គឺមានសារសំខាន់ណាស់។ ការចាត់វិធានការសកម្មក្នុងការសម្របខ្លួន និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តាមរយៈការដាក់បញ្ចូលគោលនយោបាយ គឺជាប្រការចាំបាច់ សម្រាប់គំរូអភិវឌ្ឍន៍របស់កម្ពុជា ដំណាក់កាលបន្ទាប់។

២. កម្ពុជាត្រូវកសាងភាពធន់ ដោយបង្កើតប្រព័ន្ធសេដ្ឋកិច្ចរឹងមាំ និងអភិវឌ្ឍន៍ធនធានមនុស្សរបស់ខ្លួន។ ធនធានមនុស្សមាននៅក្នុងប្រទេស នឹងទទួលបានអត្ថប្រយោជន៍ពីការចូលប្រើប្រាស់ទូលំទូលាយ និងសេវាកម្មប្រកបដោយគុណភាពក្នុងវិស័យអប់រំ សុខភាព ការបណ្តុះបណ្តាលជំនាញ និងការគាំពារសង្គម។ អភិបាលកិច្ចត្រូវតែឆ្លើយតបនឹងតម្រូវការរបស់សង្គមនៅគ្រប់លំដាប់ថ្នាក់ បើកចំហ តម្លាភាព និងគណនេយ្យភាព។

៣. ការបន្តពឹងផ្អែកលើទីផ្សារខាងក្រៅ និងការនាំចេញទំនិញ មិនមាននិរន្តរភាពនៅក្នុងគន្លងអភិវឌ្ឍន៍ "ប្រក្រតីភាពថ្មី" នោះទេ។ កំណើនសេដ្ឋកិច្ចនាពេលអនាគត ត្រូវតែបានមកពីពិពិធកម្មលើវិស័យកសិកម្ម និងផលិតកម្ម ជាមួយនឹងការផ្លាស់ប្តូរឆ្ពោះទៅរកសកម្មភាពតម្លៃបន្ថែមខ្ពស់ និងពឹងផ្អែកតិចលើវិស័យទេសចរណ៍ និងវិស័យសំណង់ និងអចលនទ្រព្យ។

៤. ការផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងតំបន់ គឺជាគន្លឹះជំរុញការតភ្ជាប់រវាងអ្នកផលិតនៅជនបទ និងទីផ្សារក្នុងតំបន់។ ការអភិវឌ្ឍណាមួយក្នុងវិស័យនេះ ត្រូវរួមបញ្ចូលការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនការធ្វើឌីជីថលនីយកម្ម។

៥. ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ជាពិសេសក្នុងការស្រាវជ្រាវ និងនវានុវត្តន៍ គឺជាកត្តាសំខាន់សម្រាប់ជំរុញសេដ្ឋកិច្ច និងជំរុញការអភិវឌ្ឍរយៈពេលវែង។ កិច្ចសហការរវាងក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាល វិស័យឯកជន និងសាកលវិទ្យាល័យ តាមរយៈការស្រាវជ្រាវ និងអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រ នឹងជំរុញដំណោះស្រាយប្រកបដោយនវានុវត្តន៍ ចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍនាពេលបច្ចុប្បន្ន និងអនាគត។

## ទិសដៅស្រាវជ្រាវគោលនយោបាយនាពេលអនាគត

សន្និសីទបានផ្តោតសំខាន់លើវិស័យខាងក្រោមសម្រាប់ការស្រាវជ្រាវនាពេលអនាគត។

**ការប្រែប្រួលអាកាសធាតុ និងសេដ្ឋកិច្ចបៃតង៖**

- កំណត់គម្រោងកាត់បន្ថយ និងបន្សាំអាកាសធាតុដែលអាចសម្រេចបាន ដែលរដ្ឋាភិបាល និងអ្នកវិនិយោគត្រូវអភិវឌ្ឍ និងវិនិយោគ។ ការវិនិយោគលើគម្រោងបែបនេះ អាចទប់ទល់នឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ គាំទ្រដល់វិស័យសេដ្ឋកិច្ចមានស្រាប់ និងផ្តល់ផលចំណេញសេដ្ឋកិច្ចខ្ពស់។

**បច្ចេកវិទ្យាឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម ៤.០៖**

- ស្រាវជ្រាវឱកាសសម្រាប់ការវិនិយោគផ្ទាល់ពីបរទេសដែលផ្តោតលើសេដ្ឋកិច្ចឌីជីថល និងនវានុវត្តន៍ដើម្បីបញ្ចូលប្រទេសកម្ពុជានៅក្នុងបដិវត្តន៍ឧស្សាហកម្ម ៤.០។
- ដោយមើលឃើញពីចក្ខុវិស័យសេដ្ឋកិច្ចបច្ចុប្បន្ន ការស្រាវជ្រាវពីឱកាសជាសក្តានុពលសម្រាប់កម្ពុជាក្នុងការលោតផ្លោះដោយផ្ទាល់ទៅក្នុងសេដ្ឋកិច្ចឌីជីថល និងស្វែងរកមធ្យោបាយជំរុញនវានុវត្តន៍ថ្មីនៅក្នុងប្រទេសតូចៗ និងកំពុងអភិវឌ្ឍ។

**ឧស្សាហកម្មថ្មីសម្រាប់កំណើនដោយគុណភាព៖**

- គិត និងពិចារណាលើប្រព័ន្ធអេកូឡូស៊ីធុរកិច្ចតាមវិស័យនីមួយៗ ដើម្បីកំណត់កត្តាដែលរារាំងដល់ការអភិវឌ្ឍវិស័យទាំងនោះ និងស្នើដំណោះស្រាយដើម្បីដោះស្រាយបញ្ហាទាំងនោះ។
- ស្រាវជ្រាវវិស័យកំណើនថ្មី ដែលអាចគាំទ្រដល់សសរស្តម្ភសេដ្ឋកិច្ចសំខាន់ៗរបស់ប្រទេសកម្ពុជាគឺ កសិកម្ម ផលិតកម្ម ទេសចរណ៍ និងឧស្សាហកម្មថ្មីៗកំពុងកើតឡើង។

**អាទិភាពគោលនយោបាយសំខាន់ៗសម្រាប់រដ្ឋាភិបាល៖**

- ស្រាវជ្រាវ និងកំណត់អាទិភាពកំណែទម្រង់គោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។




សម្រាប់ព័ត៌មានបន្ថែមនៃសន្និសីទនេះ សូមមើលគេហទំព័រ៖
https://coc2022.cdri.org.kh

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

អាសយដ្ឋានៈ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទៈ +៨៥៥ ២៣ ៨៨១ ៣៨៤, ៨៨១ ៧០១,
៨៨១ ៩១៦, ៨៨៣ ៦០៣
អ៊ីម៉ែលៈ cdri@cdri.org.kh គេហទំព័រៈ www.cdri.org.kh